https://construction-property.com/km/investment-projects-worth-close-to-us2-billion-approved/ Go SEP OCT NOV
1 capture 02
2 Oct 2023 2022 2023 2024 About this capture

060 888 944 - 077 811 168 info@construction-property.com



# ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាអនុម័តគម្រោងវិនិយោគជាងជិត ២ពាន់លានដុល្លារ

២៦ ធ្នូ ២០១៩ ព័ត៌មានក្នុងស្រុក 4068 មើល



ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តគម្រោងវិនិយោគនៅចុងខែធ្នូនេះ ជាច្រើនគម្រោងទាក់ទងទៅនឹងអគ្គិសនី ផ្សារទំនើប និងសណ្ឋាគារលំដាប់ផ្កាយ៥ ដែលមានទឹកប្រាក់វិនិយោគប្រមាណ ១.៦ពាន់លានដុល្លារ។

យោងតាមព័ត៌មានកាលពីថ្ងៃទី២៥ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័តលើគម្រោងសាងសង់សណ្ឋាគារ និងអគារពាណិជ្ជកម្ម ចំនួនពីរក្រុមហ៊ុន ក្នុងនោះ ក្រុមហ៊ុន BOCC DEVELOPMENT CO.,LTD សាងសង់សណ្ឋាគារលំដាប់ថ្នាក់ផ្កាយ៥ ចំនួន៥០០បន្ទប់ សាងសង់អគារ Service Hotel Apartment ថ្នាក់ផ្កាយ៤ ចំនួន ១៦០០ យូនីត និងសាងសង់មជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានទីតាំងវិនិយោគស្ថិតនៅ កោះពេជ្រ មានទុនវិនិយោគសរុប ១ ១៨១ លានដុល្លារ។

ក្រុមហ៊ុន XIN DA SHI JIE INTERNATIONAL HOTEL CO.,LTD សាងសង់ និងអាជីវកម្មសណ្ឋាគារថ្នាក់ផ្កាយ៥ ចំនួន១៥០០បន្ទប់ និងមជ្ឈមណ្ឌលពាណិជ្ជកម្ម ដែលមានទីតាំង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

មានទុនវិនិយោគប្រមាណ ៣៣១ លានដុល្លា។

ដោយឡែក ទាក់ទងនឹងការវិនិយោគលើវិស័យអគ្គិសនីវិញ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុញ្ញាតឲ្យក្រុមហ៊ុនចំនួនពីរ ក្នុងនោះ ក្រុមហ៊ុន SCHNEITEC POWER CO., LTD វិនិយោគគម្រោងសាងសង់ខ្សែបណ្ដាញបញ្ជូន និងអនុស្ថានីយអគ្គិសនី មានទុនវិនិយោគប្រមាណ ៧១លានដុល្លារ នៅខេត្តព្រះសីហនុ និងក្រុមហ៊ុន SCHNEITEC INFINITE CO., LTD វិនិយោគសាងសង់ស្ថានីយផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ កម្លាំង ៣០មេហ្គាវ៉ាត់ នៅខេត្តពោធិ៍សាត់ មានទុនវិនិយោគ ២៩លានដុល្លារ។

ទាក់ទងនឹងការវិនិយោគបើករោងចក្រ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័ត ឱ្យក្រុមហ៊ុន DE HEUS TMH CO., LTD វិនិយោគរោងចក្រផលិតចំណីសត្វ ដែលមានទីតាំងនៅស្រុកឧត្ដុង្គ ខេត្តកំពង់ស្ពឺ មានទុនវិនិយោគ ១១លានដុល្លារ។

គម្រោងបង្កើតរោងចក្រផ្គុំដំឡើងសម្ភារៈ អេឡិចត្រូនិក វិនិយោគដោយក្រុមហ៊ុន MILLPLAN INDUSTRIES (CAMBODIA) CO.,LTD ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានទុនវិនិយោគ ៧លានដុល្លារ។

គម្រោងបង្កើតរោងចក្រផ្គុំដំឡើងគ្រឿងបរិក្ខាអគ្គិសនី និងគ្រឿង អេឡិចត្រូនិកគ្រប់ប្រភេទវិនិយោគដោយក្រុមហ៊ុន FHL INDUSTRIES CO., LTD ស្ថិតនៅស្រុកសំរោងទង ខេត្តកំពង់ស្ពឺ មានទុនវិនិយោគប្រមាណ ២.៤លានដុល្លារ។

គម្រោងបង្កើតរោងចក្រផ្គុំដំឡើងរថយន្តគ្រប់ប្រភេទ និងគ្រឿងម៉ាស៊ីន សម្ភារៈបរិក្ខាផ្សេងៗ វិនិយោគដោយក្រុមហ៊ុន CXD INDUSTRY CO.,LTD ស្ថិតនៅខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ មានទុនវិនិយោគប្រមាណ ៦លានដុល្លារ៕

- Video Advertisement -

ធុរកិច្ច និងទីផ្សារ ការវិនិយោគ និងមូលធន

## ព័ត៌មានដែលទាក់ទង



### កម្ពុជា-ថៃ ប្ដេជ្ញារួមគ្នាដោះបញ្ហាការដឹកជញ្ជូនឆ្លងដែន ដើម្បី

២៩ កញ្ញា ២០២៣

កម្ពុជា និងថៃ កំពុងរួមគ្នាដោះស្រាយបញ្ហាការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែន ដើម្បីសម្រេចទំហំ



### វៀតណាមចំណាយជិត ៨ពាន់លានដុល្លារ ទិញ

២០ កញ្ញា ២០២៣

ក្រុមហ៊ុនអាកាសចរណ៍វៀតណាម បានព្រមព្រៀងនឹងចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់មួយ ដើម្បី



### វិនិយោគិនវៀតណាម ជាង២០ក្រុមហ៊ុនជួបជាមួយ

១៩ កញ្ញា ២០២៣

សមាគមអ្នកសាងសង់កម្ពុជា ក្រោមការដឹកនាំដ៏ថ្លៃថ្នូររបស់អ្នកឧកញ៉ា ពុង ឃាវសែ ប្រធានសមាគម









### រយៈពេល៨ខែនេះ ទំហំពាណិជ្ជកម្មរវាងកម្ពុជានិង

📅 ១៣ កញ្ញា ២០២៣

ក្នុងរយៈពេល ០៨ខែ ឆ្នាំ២០២៣នេះ ការធ្វើពាណិជ្ជកម្មផ្លាស់ប្តូរទំនិញរវាងកម្ពុជា និងអន្តរជាតិ មានទំហំ



### ក្រុមហ៊ុនផលិតបន្ទះសូឡាធំ១នៅកម្ពុជា គ្រោងពង្រីកខ្លួន

📅 ១៣ កញ្ញា ២០២៣

ក្រុមហ៊ុន New East Solar Energy ដែលមានទីស្នាក់ការកណ្ដាលនៅកម្ពុជា នឹងបើករោងចក្រ



### វៀតណាមក្លាយជាតួអង្គសំខាន់ក្នុងយុទ្ធសាស្ត្រធ្វើពិពិធកម្ម

📅 ១២ កញ្ញា ២០២៣

ដំណើរទស្សនកិច្ចរបស់លោកប្រធានាធិបតីអាមេរិក ចូ បៃដិន (Joe Biden) ទៅកាន់

## លេខចុងក្រោយ









## ផ្សព្វផ្សាយពាណិជ្ជកម្ម



Copyright © 2019 Construction Property, All Rights Reserved.